**【សេចក្តីណែនាំអំពីកម្មវិធីពិនិត្យសុខភាព】**

សេវាធានារ៉ាប់រងសុខភាពជាតិផ្តល់នូវជំនួយថែទាំសុខភាពដល់អ្នកទទួល និងការធានារ៉ាប់រងសុខភាពដល់អ្នកជាវ តាមរយៈការពិនិត្យសុខភាព។ គោលបំណងនៃការពិនិត្យសុខភាព គឺដើម្បីបង្ការជំងឺ ឬរកឃើញជំងឺនៅដំណាក់កាលដំបូង ដើម្បីបង្ការកុំឲ្យជំងឺកាន់តែធ្ងន់ធ្ងរ ហើយវិធានាការសមស្របអាចធ្វើឡើង ដើម្បីថែទាំសុខភាពឲ្យបានល្អ។

♠ **ការពិនិត្យសុខភាពទូទៅ**មានគោលបំណងដើម្បីបង្ការ និងពិនិត្យរកជំងឺបេះដូង និងជំងឺខួរក្បាល ដូចជា ជំងឺសម្ពាធឈាមខ្ពស់ និងជំងឺទឹកនោមផ្អែម។ ការពិនិត្យផ្តោតគោលដៅទៅលើអ្នកទាំងឡាយដែលមានអាយុលើសពី ម្ភៃ ឆ្នាំ ហើយត្រូវធ្វើឡើងម្តងរៀងរាល់ ២ ឆ្នាំ។ ទោះជាយ៉ាងណា គ្មានការកំណត់អាយុសម្រាប់អ្នកទាំងឡាយដែលជាសមាជិកគ្រួសារ និងជាសមាជិកធ្វើការងារទេ ហើយការពិនិត្យនេះត្រូវធ្វើឡើងម្តងរៀងរាល់មួយឆ្នាំ សម្រាប់អ្នកទាំងឡាយដែលធ្វើការងារ តែមិននៅក្នុងការិយាល័យ។

♠ **ការពិនិត្យសុខភាពមាត់ធ្មេញ** ត្រូវបានធ្វើឡើងសម្រាប់ការស្វែងរកឃើញជំងឺឆ្លងមាត់ធ្មេញជាមុន ដូចជាជំងឺដង្កូវ ស៊ីធ្មេញ ជំងឺអញ្ចាញធ្មេញ ជាដើម សម្រាប់ប្រធានបទពិនិត្យសុខភាពទូទៅ។

♠ **ការពិនិត្យរកជំងឺមហារីក** ផ្តោតលើជំងឺមហារីកធំចំនួនប្រាំមួយដែលមានអត្រាកើតខ្ពស់ ដែលអាចពិនិត្យឃើញនៅដំណាក់កាលដំបូង តាមរយៈវិធីសាស្ត្រសាមញ្ញ ហើយអាចព្យាបាលបាន។ ប្រភេទនៃការពិនិត្យរកជំងឺមហារីកនិងអ្នកជំងឺ រួមមានជំងឺមហារីកក្រពះនិងជំងឺមហារីកសុដន់ចំពោះបុគ្គលអាយុលើស40ឆ្នាំ ជំងឺមហារីកពោះវៀនធំចំពោះបុគ្គលអាយុលើស50ឆ្នាំ ជំងឺមហារិកស្បូនចំពោះស្ត្រីអាយុលើស20ឆ្នាំ ជំងឺមហារីកថ្លើមចំពោះបុគ្គលអាយុលើស40ឆ្នាំដែលមានហានិភ័យខ្ពស់ និងជំងឺមហារីកសួតចំពោះបុគ្គលអាយុចន្លោះ54ដល់74ឆ្នាំ ដែលជក់បារីមួយថ្ងៃមួយកញ្ចប់ ក្នុងរយៈពេល30ឆ្នាំ។ ចន្លោះពេលពិនិត្យ គឺរៀងរាល់ពីរឆ្នាំម្តងចំពោះជំងឺមហារីកក្រពះ សុដន់ ស្បូន និងសួត, មួយឆ្នាំម្តង ចំពោះជំងឺមហារីកពោះវៀនធំ និងពីរដងក្នុងមួយឆ្នាំចំពោះជំងឺមហារីកថ្លើម។

♠ **ការពិនិត្យសុខភាពទារក** រួមមានការពិនិត្យការរីកធំលូតលាស់ធម្មតារបស់ទារក ដែលរាប់បញ្ចូលទាំងការវាយតម្លៃការលូតលាស់ និងការប្រឹក្សាអំពីការថែទាំទារក ដែលឆ្លុះបញ្ចាំងពីការអប់រំសុខភាព។ ទារកដែលមានលក្ខណៈសម្បត្តិអាចធ្វើការត្រួតពិនិត្យរហូតដល់ ១០ សម្រាប់កុមារអាយុក្រោម ៦ ឆ្នាំ នៅវ័យ ៤ ៩ ១៨ ៣០ ៤២ ៥៤ និង ៦៦ខែ ដែលរាប់បញ្ចូលទាំងការពិនិត្យមាត់ធ្មេញផងដែរ។

**【ថ្លៃចំណាយនៃការពិនិត្យសុខភាព】**

♠ ការចំណាយពិនិត្យសុខភាពទូទៅ និងការពិនិត្យសុខភាពរបស់ទារក នឹងទទួលខុសត្រូវពេញលេញដោយសាជីវកម្ម។
ដូច្នេះគ្មានការចំណាយបន្ថែមទៀតត្រូវទទួលខុសត្រូវដោយអ្នកត្រួតពិនិត្យក្នុងកំឡុងពេលពិនិត្យសុខភាពឡើយ។

♠ ពាក់ព័ន្ធនឹងការពិនិត្យជំងឺមហារីកនេះ ចំណាយពិនិត្យសុខភាព 90% នឹងទទួលខុសត្រូវដោយក្រុមហ៊ុនសាជីវកម្ម ហើយនៅសេសសល់ 10% នឹងទទួលខុសត្រូវដោយដោយអ្នកពិនិត្យ។
ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ការពាក់ព័ន្ធនឹងការពិនិត្យជំងឺមហារីកមាត់ស្បូន និងជំងឺមហារីកពោះវៀនធំ នឹងទទួលខុសត្រូវពេញលេញដោយសាជីវកម្ម។

♠ ទាក់ទងនឹងថ្លៃចំណាយពិនិត្យមហារីក ដែលជាអ្នកចូលរួមពិនិត្យរកមហារីកនៃកម្មវិធីជាតិ (សរសេរលើតារាង) ពិនិត្យរហូតដល់កម្រិតនៃថ្លៃទិញធានារ៉ាបរង ប្រទេសជាអ្នកទទួលបន្ទុកបង់ ១0% នៃថ្លៃចំណាយសម្រាប់ត្រួតពិនិត្យ ដូច្នេះ អ្នកទទួលការពិនិត្យមិនជាប់បន្ទុកបង់ចំណាយអ្វីឡើយ។ .

**【នីតិវិធីពិនិត្យសុខភាព】**

♠ ពិនិត្យឈ្មោះអ្នកចូលរួមក្នុងការពិនិត្យសុខភាព
ឆែករកពេល និងឈ្មោះអ្នកចូលរួម តាមរយៈលិខិតបញ្ជាក់ពីការពិនិត្យ ដែលសាជីវកម្មបានបញ្ជូន (ទៅលំនៅដ្ឋាន ឬកន្លែងធ្វើការ) ទៅឲ្យអ្នកចូលរួម ។

♠ ធ្វើការណាត់ជួប និងធ្វើដំណើរទៅទីភ្នាក់ងារពិនិត្យសុខភាព។
លោកអ្នកអាចកំណត់ពេលធ្វើតេស្តពិនិត្យសុខភាព នៅមន្ទីរពេទ្យណាបានដែលមានការអនុញ្ញាត ទោះបីលោកអ្នករស់នៅក្នុងតំបន់ណាក៏ដោយ។ សូមយកអត្តសញ្ញាណ និងកាតពិនិត្យសុខភាពរបស់លោកអ្នកមកជាមួយ នៅពេលណាត់ជួប។

♠ ការជូនដំណឹងពីលទ្ធផលនៃការពិនិត្យ
លទ្ធផលពិនិត្យត្រូវផ្ញើតាមប្រៃសណីយ៍ទៅតាមព័ត៌មានទំនាក់ទំនងរបស់អ្នកត្រួវពិនិត្យ ដោយភ្នាក់ងារពិនិត្យ នៅនឹងកន្លែងដែលការពិនិត្យកើតមានឡើង ហើយការពិនិត្យបញ្ជាក់ត្រូវធ្វើឡើងលើអ្នកណាដែលត្រូវបានសង្ស័យ ដោយផ្អែកលើលទ្ធផលពិនិត្យសុខភាពទូទៅ។

**【ការត្រៀមខ្លួនមុនពេលធ្វើការពិនិត្យសុខភាព】**

♠ លោកអ្នកមិនត្រូវតមអាហារបន្ទាប់ពីម៉ោង ៩ យប់ មួយថ្ងៃមុនធ្វើការត្រួតពិនិត្យ។
- គួរតមអាហារយ៉ាងហោចណាស់ ៨ ម៉ោង
- លទ្ធផលនៃការពិនិត្យអាចមិនត្រឹមត្រូវទេ ប្រសិនបើអ្នកទទួលការពិនិត្យ ពុំបានតមអាហារនោះ។.

♠ សូមជៀសវាងកុំធ្វើការត្រួតពិនិត្យសុខភាព ក្នុងអំឡុងពេលមករដូវ (ប្រហែល២-៣ ថ្ងៃ មុន ឬក្រោយពេលមករដូវ)

♠ ការពិនិត្យសុខភាពអាចធ្វើត្រឹមចំនួនកំណត់ប៉ុណ្ណោះ ហើយក្នុងករណីទទួលលើសចំនួនកំណត់ អ្នកទទួលការពិនិត្យត្រូវបង់សងថ្លៃចំណាយវិញ។

សេចក្តីណែនាំអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព
ព័ត៌មានអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព _ ភាសាអង់គ្លេស
ព័ត៌មានអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព _ ភាសាចិន
ព័ត៌មានអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព _ ភាសាជប៉ុន
ព័ត៌មានអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព _ ភាសាវៀតណាម
ព័ត៌មានអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព _ ហ្វីលីពីន (Tagalog)
ព័ត៌មានអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព _ ភាសាថៃ
ព័ត៌មានអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព _O'zbek tili
ព័ត៌មានអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព _ ភាសាម៉ុងហ្គោលី
ព័ត៌មានអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព _ ភាសាខ្មែរ
ព័ត៌មានអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព _ ភាសានេប៉ាល់
ព័ត៌មានអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព _ ភាសាឥណ្ឌូនេស៊ី
ព័ត៌មានអំពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព _ ស៊ីនហាឡា
ព័ត៌មានកម្មវិធីពិនិត្យសុខភាព_រុស្ស៊ី
ព័ត៌មានស្តីពីកម្មវិធីពិនិត្យរកបញ្ហាសុខភាព_ភាសាមីយ៉ាន់ម៉ារ

"យើងធ្វើកិច្ចការតិចតួច ដើម្បីឲ្យលោកអ្នកបន្តសប្បាយរីករាយ សេវាធានារ៉ាប់រងសុខភាពជាតិនៅជាមួយលោកអ្នក"។

ក្រសួងសុខាធិបាល និងសុខមាលភាព
សេវាធានារ៉ាប់រងសុខភាពជាតិ

【ដំបូន្មានទាំង ៩ សម្រាប់បង្ការជំងឺបេះដូង និងខួរក្បាល】
<យោង៖ ក្រសួងសុខាភិបាល និងសុខមាលភាព>
១_ឈប់ជក់បារី។
២_កាត់បន្ថយការបរិភោគគ្រឿងស្រវឹងមកត្រឹម ១ ឬ ២ កែវក្នុងមួយថ្ងៃ។
៣_រក្សារបបអាហារមានសុខភាពល្អ ហើយបរិភោគបន្លែ និងត្រីឲ្យបានច្រើន។
៤_ព្យាយាមហាត់ប្រាណលើសពី ៣0 នាទីក្នុងមួយថ្ងៃ ពេលណាអាចធ្វើទៅបាន។
៥_រក្សាទម្ងន់ឲ្យបានត្រឹមត្រូវ។ វាស់ចង្កេះជាប្រចាំ។
៦_រកវិធីកាត់បន្ថយស្ត្រេស និងធ្វើឲ្យចិត្តសប្បាយរីករាយ។
៧_វាស់សម្ពាធឈាមជាប្រចាំ និងពិនិត្យជាតិស្ករ និងខូលេស្តេរ៉ុល។
៨_កាត់បន្ថយ និងព្យាបាលរោគសម្ពាធឈាមខ្ពស់ ជំងឺទឹកនោមផ្អែម និងជាតិខ្លាញ់ខ្ពស់ក្នុងឈាម។
៩_កត់សម្គាល់រោគសញ្ញាដាច់សរសៃឈាមក្នុងខួរក្បាល និងគាំងបេះដូង ហើយក្នុងករណីសង្គ្រោះបន្ទាន់ ត្រូវស្វែងរកការថែទាំវេជ្ជសាស្ត្រភ្លាមៗ។

【គេហទំព័ររបស់ HNIS ជាភាសាបរទេស】
☞ http://www.nhis.or.kr/english/
☞ http://www.nhis.or.kr/japanese/
☞ http://www.nhis.or.kr/chinese/
☞ http://www.nhis.or.kr/vietnamese/

【ផ្នែកឆ្លើយឆ្លងទូរសព្ទជាភាសាអង់គ្លេសនៃ NHIS】
☎ 033-811-2000
【បញ្ជីសំណួរភាសាសញ្ញា និងព័ត៌មានពិនិត្យសុខភាព】គេហទំព័រសុខភាព iN